ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

**សេចក្តីប្រកាសព័ត៌មាន**
**ស្តីពី**
**ការមិនទទួលស្គាល់ ឧបករណ៍ BitCoin និងឧបករណ៍**
**អេឡិចត្រូនិកដែលមានលក្ខណៈប្រហាក់ប្រហែល**
**នៅទីផ្សារប្រទេសកម្ពុជា**

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន គ្រឹះស្ថាន-ស្ថាប័ននានា ឲ្យបានជ្រាបថា ធនាគារជាតិនៃកម្ពុជា មិនទទួលស្គាល់ឧបករណ៍ BitCoin និងឧបករណ៍អេឡិចត្រូនិកដែលមានលក្ខណៈប្រហាក់ប្រហែល ជារូបិយប័ណ្ណ ឬជាឧបករណ៍ទូទាត់ស្របច្បាប់នៅប្រទេសកម្ពុជាទេ ។

ធនាគារជាតិនៃកម្ពុជាយល់ឃើញថា ឧបករណ៍ BitCoin នេះ អាចមានហានិភ័យដល់អ្នកប្រើប្រាស់ និងសង្គមជាតិ ដូចជា ពុំមានគោលការណ៍ការពារអតិថិជន (Consumer Protection) អ្នកប្រើប្រាស់អាចប្រើឈ្មោះលួចលាក់ដើម្បីបើកគណនី BitCoin ពោលគឺមានលក្ខណៈអនាមិកដែលងាយរងនិង Cyber-Crime ដូចជាត្រូវបាន Hacked បំផ្លាញដោយវីរុស ឬលុបដោយចៃដន្យ និងជាមធ្យោបាយសម្រាប់ការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងទីផ្សារងងឹត ។ ជាងនេះទៅទៀត រហូតមកដល់បច្ចុប្បន្ន ការប្រើប្រាស់ BitCoin នៅបណ្តាប្រទេសផ្សេងៗនៅមិនទាន់មានការទទួលស្គាល់ និងស្ថិតក្នុងយុត្តាធិការរបស់ធនាគារកណ្តាលណាមួយនៅឡើយទេ ។

អាស្រ័យហេតុនេះ សូមសាធារណជន និងគ្រឹះស្ថាន-ស្ថាប័នទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងប្រុងប្រយ័ត្នចំពោះហានិភ័យដែលអាចកើតឡើង ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១៤

ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧